សៀវភៅណែនាំស្ដីអំពី

# កិច្ចសន្ទនា សកម្មភាព និងការចូលរួមនៅថ្នាក់មូលដ្ឋាន (LEAD)



EarthRights International

# សេចក្ដីផ្ដើមអំពី សំណុំឧបករណ៍ LEAD

## មាតិកា


សេចក្តីផ្តើម និង សារតារ ១

១.

វិធីសាស្រ្តរបស់ LEAD ២

១.១ តើ LEAD ជាអ្វី? ២

១.២ ហេតុអ្វីបានជាត្រូវប្រើ LEAD? ២

១.៣ គុណតម្លៃស្នូល ៣

១.៤ ភាគីពាក់ព័ន្ធ ៣

២.

២. ធាតុផ្សំចំនួនបីក្នុង "ការកសាង" នៅក្នុងយន្តការ LEAD ៤

២.១ ឧបករណ៍ដែលជាធាតុផ្សំរបស់ LEAD ៥

២.២ ការកសាងជំនឿទុកចិត្ត ៦

២.៣ ការកសាងសហគមន៍ ៧

២.៤ ការរៀបចំយុទ្ធនាការ ១០

៣.

LEAD និងសិទ្ធិមនុស្ស ១៣

៤.

របៀបប្រើប្រាស់ឧបករណ៍នេះ ១៤

# សេចក្តីផ្តើម និងសារតារ

អង្គការសិទ្ធិផែនដី (EarthRights) ធ្វើការក្នុងគោលបំណងដើម្បីបញ្ចប់ការរំលោភបំពានសិទ្ធិមនុស្សនិង ភាពអយុត្តិធម៌ផ្នែកអាកាសធាតុ តាមរយៈការផ្លាស់ប្តូរអំណាចត្រឡប់ទៅឲ្យសហគមន៍ជួរមុខវិញ។ អង្គការសិទ្ធិផែនដី (EarthRights) ជឿជាក់ថាសហគមន៍ ត្រូវតែស្ថិតនៅចំណុចស្នូលកណ្តាលនៃការធ្វើសកម្មភាពនិងការធ្វើយុទ្ធនាការក្នុងការការពារសិទ្ធិរបស់ខ្លួន និងទាមទារអោយមានគណនេយ្យភាពពីសំណាក់សាជីវកម្មពហុជាតិ និងរដ្ឋាភិបាលដែលបានរំលោភបំពានសិទ្ធិរបស់ពួកគេ។ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនេះ អង្គការសិទ្ធិផែនដី (EarthRights) តាមរយៈក្រុមអ្នកធ្វើយុទ្ធនាការ ក្រុមអ្នកច្បាប់ និងក្រុមអ្នកបណ្តុះបណ្តាលរបស់ខ្លួន បានធ្វើការ ទន្ទឹមគ្នាជាមួយសហគមន៍ ដើម្បីរៀបចំនិងអនុវត្តនូវផែនការយុទ្ធនាការ ការតស៊ូមតិ និងសកម្មភាពផ្លូវច្បាប់ ព្រមទាំងកម្មវិធីបណ្តុះបណ្តាលដទៃផ្សេងទៀតប្រកបដោយប្រសិទ្ធភាព។ សកម្មភាពទាំងអស់នេះបានទាញចេញពី និង/ឬ បង្កើតបានជាឧបករណ៍ និងយុទ្ធសាស្រ្តនានា ដើម្បីជួយគាំទ្រសហគមន៍ក្នុងការអនុវត្តកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ។

ឧបករណ៍នៃកិច្ចសន្ទនា សកម្មភាព និងការចូលរួមនៅថ្នាក់មូលដ្ឋាន (LEAD) នេះ មានគោលបំណងក្នុងការ ធ្វើការកត់ត្រាអំពីវិធីសាស្រ្តធ្វើការងារទាំងអស់ របស់អង្គការសិទ្ធិផែនដី (EarthRights) ដែលផ្តោតលើការកសាងមូលដ្ឋានគ្រឹះរបស់សហគមន៍និងដាក់បញ្ចូលនូវយុទ្ធសាស្រ្តផ្សេងៗដែលដឹកនាំ ដោយសហគមន៍មូលដ្ឋាន ព្រមទាំងឧបករណ៍នានាដែលអង្គការសិទ្ធិផែនដី (EarthRights) និងអង្គការដៃគូនានាបានប្រើ ដើម្បីដាក់បញ្ចូលទៅជាបណ្តុំឧបករណ៍តែមួយគឺ គោលការណ៍ណែនាំស្តីពី សំណុំឧបករណ៍នៃកិច្ចសន្ទនា សកម្មភាព និងការចូលរួមនៅថ្នាក់មូលដ្ឋាន (LEAD) នេះ។ ក្នុងការប្រមែប្រមូលផ្នែកផ្សេងៗទាំងអស់នេះមកដាក់បញ្ចូលគ្នា សំណុំឧបករណ៍ LEAD មានគោលបំណង ជួយដល់បុគ្គលិកនិងអង្គការដៃគូរបស់អង្គការសិទ្ធិផែនដី (EarthRights) ក្នុងការជំរុញ ការគាំទ្រដល់សហគមន៍ឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្តល់នូវប្រភពធនធានមួយ សម្រាប់ការកំណត់ និង ប្រើប្រាស់អោយបានច្រើនបំផុតនូវវិធីសាស្រ្ត សកម្មភាព និង យុទ្ធសាស្រ្តដែលពាក់ព័ន្ធ សម្រាប់ទាញការចូលរួមពីភាគីពាក់ព័ន្ធ ព្រមទាំងសកម្មភាពក្នុងការចូលរួមរបស់សហគមន៍ នៅរាល់ដំណាក់កាល នៃសកម្មភាពអាជីវកម្ម ឬគម្រោងអភិវឌ្ឍន៍។

ឯកសារនេះ សង្ខេបអំពីនូវឧបករណ៍ដែលជាធាតុផ្សំរបស់ LEAD ក្នុងការប្រើប្រាស់ដើម្បីគាំទ្រដល់ការធ្វើយុទ្ធនាការដែលដឹកនាំដោយសហគមន៍។



# ១. វិធីសាស្ត្ររបស់ LEAD

## ១.១ តើ LEAD ជាអ្វី ?

LEAD គឺជាសំណុំឧបករណ៍មួយរបស់អង្គការសិទ្ធិផែនដី (EarthRights) ដែលមានគោលបំណង ប្រមូលយកនូវវិធីសាស្ត្រដែលមានសហគមន៍មូលដ្ឋានជាស្នូល ក្នុងការធ្វើយុទ្ធនាការ ការតស៊ូមតិផ្លូវច្បាប់ និងការផ្តល់វគ្គបណ្តុះបណ្តាលផ្សេងទៀត។ ឧបករណ៍នេះ រៀបរាប់អំពីវិធីសាស្ត្រក្នុងការគាំទ្រដល់យុទ្ធនាការតស៊ូមតិដែលដឹកនាំដោយសហគមន៍មូលដ្ឋានតាមរយៈការជួយសហគមន៍ឲ្យ៖

- យល់ដឹងអំពីសិទ្ធិរបស់ខ្លួន និងកាតព្វកិច្ច របស់តួអង្គឯកជននិងរដ្ឋាភិបាលក្នុងការគោរពសិទ្ធិមនុស្ស
- កំណត់ឲ្យបាននូវសកម្មភាពដែលពួកគេអាចធ្វើឡើង ដើម្បីការពារសិទ្ធិទាំងនោះ
- រៀបចំផែនការនិងអនុវត្តយុទ្ធសាស្ត្រនានាដែលអាចជួយពង្រឹងសកម្មភាពនៃការធ្វើយុទ្ធនាការដែលដឹកនាំដោយសហគមន៍មូលដ្ឋានមួយដែលមានលក្ខណៈរឹងមាំ និង
- បង្កើនទំនុកចិត្ត ក្នុងការដឹកនាំការពារសហគមន៍របស់ពួកគេ ក្នុងរយៈពេលវែង

ឧបករណ៍ LEAD ផ្តល់ទៅអោយសហគមន៍មូលដ្ឋាននូវព័ត៌មានស្តីអំពីដំណើរការ នៃការកសាងជំនឿចិត្ត ដើម្បីគាំទ្រដល់ការរៀបចំសហគមន៍ និងដើម្បីរៀបចំនូវផែនការធ្វើយុទ្ធនាការមួយដ៏រឹងមាំ។ វាបានផ្តល់នូវសំណុំឧបករណ៍ ដែលសហគមន៍និងអង្គការដៃគូដែលគាំទ្រសហគមន៍ អាចប្រមូលផ្តុំនូវគំនិតសម្រាប់បង្កើតជាយុទ្ធសាស្ត្រ និងឧបករណ៍ជាក់លាក់នានា ដើម្បីជួយសហគមន៍ក្នុងការពង្រឹងជំនឿចិត្តនិងជំនាញរបស់ខ្លួន ដើម្បីការពារសិទ្ធិរបស់ពួកឲ្យបានកាន់តែប្រសើរ។

ដោយសារតែ LEAD គឺជាវិធីសាស្ត្រក្នុងការធ្វើការដែលផ្តោតទៅលើសហគមន៍មូលដ្ឋានជាស្នូល នោះសំណុំវិធាននេះ ត្រូវបានប្រើមិនសំដៅជាបណ្តុំនៃគោលការណ៍ណែនាំ ឬវិធាននានាដែលមានភាពតឹងរឹងនោះទេ ប៉ុន្តែវាគឺជានៃឧបករណ៍ដែលរៀបរាប់នូវជម្រើសនានា ដែលអាចមានប្រយោជន៍ចំពោះសហគមន៍។ សកម្មភាពនិងឧបករណ៍ទាំងនេះ ត្រូវប្រើអោយស្របទៅតាមបរិបទនីមួយៗ ហើយសហគមន៍ គឺជាអ្នកសម្រេចចិត្តថាតើសកម្មភាព ឬឧបករណ៍ណាមួយដែលមានភាពជាប់ទាក់ទង នឹងមានប្រយោជន៍បំផុត។ នៅពេលដែលវត្ថុបំណងរបស់សហគមន៍មានការប្រែប្រួល យុទ្ធសាស្ត្រ ដំណើរការ និងឧបករណ៍ជាក់លាក់ទាំងឡាយ ត្រូវតែផ្លាស់ប្តូ ដើម្បីឲ្យស្របតាមការផ្លាស់ប្តូរទាំងនោះដែរ។

## ១.២ ហេតុអ្វីត្រូវប្រើឧបករណ៍ LEAD ?

ឧបករណ៍ររបស់ LEAD ត្រូវបានប្រើប្រាសដើម្បីបំពេញអោយគ្នាទៅវិញទៅមកនូវគោលបំណងសំខាន់ចំនួនពីរ។ ទីមួយ ឧបករណ៍នេះ ផ្តល់ឲ្យសហគមន៍នូវគំនិតអភិវឌ្ឍន៍បែបយុទ្ធសាស្ត្រ និងឧបករណ៍ជាក់លាក់នានាដែលអាចមានប្រយោជន៍ សម្រាប់យុទ្ធសាស្ត្រតស៊ូមតិ យុទ្ធសាស្ត្រផ្លូវច្បាប់ ឬយុទ្ធសាស្ត្រធ្វើយុទ្ធនាការ។ លទ្ធផលដែលកើតចេញមកពីឧបករណ៍ផ្សេងៗ ក្នុងឧបករណ៍ LEAD ផ្តល់នូវឯកសារដ៏រឹងមាំ ដែលសហគមន៍អាចយកមកប្រើប្រាស់សម្រាប់សកម្មភាពតស៊ូមតិ សកម្មភាពចូលរួមក្នុងដំណើរការនៃការរួមបញ្ចូលអ្នកពាក់ព័ន្ធ ឬដំណើរការនីតិវិធីផ្លូវច្បាប់។ ទីពីរ ដំណើរការនេះគឺជាទម្រង់នៃការចង់ក្រងសហគមន៍ ដែលជួយអភិវឌ្ឍនិងពង្រឹងនូវជំនាញ សមត្ថភាព និងផលប្រយោជន៍ផ្សេងទៀតដែលនឹងជួយដល់សហគមន៍ ដើម្បីចូលរួមក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រជាក់លាក់របស់ពួកគេដោយផ្ទាល់ និងប្រកបដោយអត្ថន័យពេញលេញក៏ដូចជា ពង្រឹងការប្រើប្រាស់ជំនាញនិងទំនុកចិត្ត ក្នុងការការពារសហគមន៍របស់ខ្លួនក្នុងរយៈពេលវែង។

ឧបករណ៍ LEAD ដែលមានសហគមន៍ជាស្នូលនេះ ជួយគាំទ្រ និងបំពងសំឡេងបន្ថែម ទៅលើអំណាចនិងចំណេះដឹងដែលសហគមន៍មានរួចជាស្រេច ។ ឧបករណ៍នេះនឹងជួយផ្លាស់ប្តូរតុល្យភាពអំណាចដែលជារឿយៗកើតឡើងរវាងសហគមន៍នានានិងតួអង្គផ្សេងទៀតដែលមានការពាក់ព័ន្ធនៅក្នុងគម្រោង ដូចជាក្រុមហ៊ុននិងរដ្ឋាភិបាល។ ឧបករណ៍ LEAD មានលក្ខណៈបត់បែននិងអាចសម្របទៅតាមកាលៈទេសៈបាន ហើយដែលអាចមានប្រយោជន៍សម្រាប់សហគមន៍ នៅក្នុងបរិបទនយោបាយផ្សេងៗគ្នា ហើយដែលជួនកាលបរិបទមានស្ថានភាពសើបខ្លាំង និងមានភាពប្រឈមខ្ពស់។ វាផ្តល់ជូនសហគមន៍នូវការធ្វើផែនការសកម្មភាពដែលមានលក្ខណៈយុទ្ធសាស្ត្រហើយអាចអនុវត្តបានប្រកបដោយ

ប្រសិទ្ធភាព ហើយឧបករណ៍នេះអាចយកទៅប្រើប្រាស់ដើម្បីរៀបចំយុទ្ធសាស្ត្រតស៊ូមតិ និងដើម្បីគាំទ្រវត្ថុបំណងនៃការធ្វើយុទ្ធនាការតស៊ូមតិរបស់ពួកគេអោយកាន់តែមានប្រសិទ្ធភាព។ ភាពបត់បែននេះក៏មានន័យដែរថា ឧបករណ៍និងសកម្មភាពទាំងអស់នោះ អាចប្រើប្រាស់ដាច់ដោយឡែកពីគ្នា ឬប្រើរួមគ្នាបាន ហើយក៏មានន័យដែរថា វិធីសាស្ត្រទាំងនេះនៅតែបន្តមានប្រយោជន៍បើ ទោះបីជាវត្ថុបំណងរបស់សហគមន៍មានការប្រែប្រួលក៏ដោយ។

## ១.៣ គុណតម្លៃស្នូល

ដើម្បីឲ្យស្របជាមួយនឹងវិធីសាស្ត្រធ្វើការរបស់អង្គការសិទ្ធិផែនដី (EarthRights) ដែលផ្តោតទៅលើសហគមន៍មូលដ្ឋាន ក្នុងប្រតិបត្តិការងាររបស់ខ្លួន ឧបករណ៍ LEAD ផ្តោតជុំវិញគុណតម្លៃស្នូលមួយចំនួនដូចខាងក្រោម៖

- <u>ការដាក់សហគមន៍ជាចំណុចស្នូល</u> ៖ សហគមន៍គឺជាធនធានចំណេះដឹងដ៏សំខាន់ ជាអ្នកជំរុញឲ្យមានការផ្លាស់ប្តូរ និងជាអ្នកធ្វើការសម្រេចចិត្ត។ ដៃគូគាំទ្រ គួរមើលឃើញតួនាទីរបស់ខ្លួនថា ជាសម្ព័ន្ធមិត្ត គឺមិនមែនជាអ្នកដឹកនាំទេ។
- <u>ការប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់និងការលើកកម្ពស់ការចូលរួម</u>៖ យុទ្ធសាស្ត្រដែលបានជ្រើសរើសគួរចាប់ផ្តើមចេញពី និងកសាងបន្ថែមទៅលើចំណេះដឹងនិងដំណើរការសម្រេចចិត្តតាមបែបប្រពៃណី ដែលសហគមន៍មានស្រាប់និងកំពុងប្រើប្រាស់រួចទៅហើយ។ ស្របពេលជាមួយគ្នានេះដែរ យុទ្ធសាស្ត្រដែលប្រើ គួរលើកទឹកចិត្តនិងគាំទ្រឲ្យមានការចូលរួមប្រកបដោយបរិយាប័ន្នពីសហគមន៍ទាំងមូល។ នេះមានន័យថា ជាការធ្វើការដើម្បី ឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងសហគមន៍ និងជួយបំពងសំឡេងរបស់ក្រុមទាំងអស់ ជាពិសេសក្រុមមនុស្សដែលច្រើនតែត្រូវបានគេផាត់ចេញ។
- <u>ការប្តេជ្ញាចិត្តរយៈពេលវែង</u>៖ ការគាំទ្រ មិនមែនផ្អែកទៅតាមគម្រោងនោះទេ ហើយមិនគួរបញ្ឈប់ នៅពេលដែលសកម្មភាពយុទ្ធនាការណាមួយ បញ្ចប់នោះឡើយ។ ដៃគូ គួរតែមានការប្តេជ្ញាចិត្តក្នុងការគាំទ្ររយៈពេលវែង ហើយដកថយវិញ តែនៅពេលណាដែលសហគមន៍លែងត្រូវការពួកគេតែប៉ុណ្ណោះ។
- <u>ការផ្តល់អាទិភាពទៅលើសុវត្ថិភាព សន្តិសុខ និងសុខុមាលភាពរបស់សហគមន៍</u>៖ ការតស៊ូមតិដើម្បីទាមទារសិទ្ធិ អាចដាក់សហគមន៍ក្នុងសភាពហានិភ័យ ហើយអាចរំខាន ដល់ជីវិតរស់នៅរបស់ពួកគេ តាមវិធីផ្សេងៗ។ អ្នកការពារសិទ្ធិផែនដី អាចមានហានិភ័យខ្លាំងនៅក្នុងពេលធ្វើការងាររបស់ខ្លួន។ ការអភិវឌ្ឍយុទ្ធសាស្ត្រដោយប្រើឧបករណ៍ LEAD ត្រូវតែពិចារណាទៅលើហានិភ័យនៅក្នុងបរិបទនីមួយៗ ក៏ដូចជាផលប៉ះពាល់ដែលអាចកើតមានទៅលើជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ជួយសហគមន៍ក្នុងការកំណត់ឲ្យបានអំពីរបៀបតម្រង់ទិសដៅសម្រាប់ បញ្ហាទាំងអស់នោះ ឲ្យបានល្អប្រសើរបំផុត និងផ្តល់ការគាំទ្រ ប្រសិនបើមានបញ្ហាកើតឡើង។

## ១.៤ ភាគីពាក់ព័ន្ធ

យោងតាមគុណតម្លៃស្នូលខាងលើ តួនាទីរបស់ដៃគូណាមួយ ដូចជាអង្គការសិទ្ធិផែនដី (EarthRights) គឺដើម្បីគាំទ្រដល់ កិច្ចប្រឹងប្រែងរបស់សហគមន៍ ។ តួនាទីរបស់ដៃគូ គឺ មិនមែនជាការបង្គាប់ឲ្យធ្វើ ឬដើរតួជា អ្នកធ្វើការសម្រេចចិត្តនោះទេ ហើយត្រូវផ្តល់អាទិភាពទៅលើសុវត្ថិភាពសន្តិសុខរបស់សហគមន៍។

ក្នុងគោលបំណងដើម្បីគាំទ្រការរៀបចំយុទ្ធសាស្ត្រឲ្យមានប្រសិទ្ធភាពជាមួយសហគមន៍ បុគ្គលិកអង្គការសិទ្ធិផែនដី (EarthRights)ដែលពាក់ព័ន្ធមានទំនួលខុសត្រូវក្នុងការឈ្វេងយល់អំពីឧបករណ៍ និងសកម្មភាពនានា ដែលមានបញ្ចូលនៅក្នុងឧបករណ៍ LEAD។ វានឹងជួយដល់សហគមន៍នៅក្នុងការកំណត់គោលដៅរបស់ខ្លួន ដែលមានលក្ខណៈជាយុទ្ធសាស្ត្រដ៏រឹងមាំមួយ។ ការគាំទ្របន្ថែមពីដៃគូផ្សេងទៀតដែលមានបទពិសោធន៍នៅក្នុងយុទ្ធសាស្ត្រជាក់លាក់ ឬឧបករណ៍ជាក់លាក់ណាមួយ អាចត្រូវបានយកមកប្រើបានប្រសិនបើមានប្រយោជន៍។

តម្លាភាព និងការគ្រប់គ្រងការរំពឹងទុកក៏មានសារៈសំខាន់ខ្លាំងដែរ។ ដោយសារតែឧបករណ៍ទាំងអស់នេះនឹងត្រូវដឹកនាំនិងចាត់ចែងការប្រើប្រាស់ដោយសហគមន៍នោះដៃគូនានាត្រូវតែមានភាពច្បាស់លាស់អំពីការប្តេជ្ញាចិត្ត ដាក់ពេលវេលា និងកម្រិតនៃការងារដែលតម្រូវក្នុងការអនុវត្តឧបករណ៍និងសកម្មភាពនានាដែលសហគមន៍បានជ្រើសរើស។ គួរតែពិភាក្សាដោយបើកចំហអំពីសក្តានុពលក៏ដូចជាដែនកំណត់នៃឧបករណ៍នីមួយៗ។ ជាការសំខាន់ណាស់ ដែលត្រូវបញ្ជាក់ឲ្យច្បាស់ថា មិនមានឧបករណ៍ណាមួយក្នុងចំណោមឧបករណ៍ទាំងអស់ អាចផ្តល់នូវការធានាថាដឹងតែទទួលបានជោគជ័យទាំងស្រុងនោះទេ។



# ២. ធាតុផ្សំចំនួនបីក្នុង "ការកសាង" នៅក្នុងយន្តការ LEAD




ឧបករណ៍ LEAD ផ្តោតទៅលើដំណើរការនៃ «ការកសាង» ជាអាទិ៍ ការកសាងជំនឿចិត្ត ការកសាង/រៀបចំសហគមន៍ និងការកសាង/រៀបចំយុទ្ធនាការ។ យើងអាចនឹកស្រមៃអំពីដំណើរការទាំងអស់នេះ ដូចជាសួនច្បារមួយ ដែលមានឫសរបស់វាប្រៀបបាននឹងយុទ្ធសាស្ត្រ - ឧបមាថាជាសកម្មភាព ហើយផ្កា គឺ ជាគោលដៅ។ កាលណាមានឫសរឹងមាំនោះ ផ្កាក៏នឹងមានឱកាសកាន់តែប្រសើរនៅក្នុងការលូតលាស់ដែរ។ ផ្កានៅក្នុងឯកសារនេះ តំណាងឲ្យគោលដៅធំទូលាយនានា ប៉ុន្តែនៅពេលយកទៅអនុវត្ត វាអាចជាវត្ថុបំណង ជាក់លាក់តូចមួយដែលបានកំណត់ដោយសហគមន៍ ។

គោលបំណងនៃការកសាងជំនឿទុកចិត្ត គឺដើម្បីបង្កើតជំនឿទុកចិត្តរវាងសហគមន៍និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការគាំទ្រសហគមន៍ដើម្បីអភិវឌ្ឍទំនាក់ទំនងដែលមានភាពរឹងមាំ មាននិរន្តរភាព និងមានសមធម៌។ គោលបំណងនៃការកសាងសហគមន៍ គឺដើម្បីគាំទ្រដល់សហគមន៍ក្នុងការអភិវឌ្ឍនូវផលប្រយោជន៍ចាំបាច់ ភាពស្អិតរមួត និងជំនាញក្នុងការកំណត់អំពីគោលដៅនិងយុទ្ធសាស្ត្រ ដើម្បីសម្រេចគោលដៅទាំងនោះ។ គោលបំណងនៃ ការរៀបចំយុទ្ធនាការ គឺដើម្បីគាំទ្រដល់សហគមន៍នៅក្នុងការអភិវឌ្ឍនិងការអនុវត្តយន្តការក្នុងការចូលរួម ការតស៊ូមតិ និងសកម្មភាពយុទ្ធនាការ អោយសម្រេចដល់គោលដៅ។

ដំណើរការផ្សេងៗគ្នានៃ «ការកសាង» នេះ គឺមានការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និតទៅវិញទៅមក ហើយអាចមានភាពស៊ីសង្វាក់គ្នា។ ឧទាហរណ៍ ការកសាងជំនឿទុកចិត្ត និងការកសាង/រៀបចំសហគមន៍ អាចជួយបង្កើតនូវទំនាក់ទំនងធ្វើការងារដែលមានការជឿជាក់ទៅវិញទៅមក រវាងសហគមន៍ និងដៃគូគាំទ្រ ហើយក៏ដើម្បីជួយពង្រឹង សមត្ថភាព និងជំនាញរបស់សហគមន៍ដែលមានស្រាប់ផងដែរ។ ចំណុចទាំងអស់នេះ ជួយពង្រឹងគោលដៅដែលទាក់ទងជាមួយនឹងការធ្វើយុទ្ធនាការរបស់ពួកគេ។ ជម្រើសផ្សេងទៀតគឺថា សហគមន៍ប្រហែលជាត្រូវការ ការគាំទ្រ ប៉ុន្តែពួកគេអាច និងមិនទាន់មានបណ្តាញ ឬសម្ព័ន្ធមិត្តដែលមានសក្តានុពលនៅឡើយទេ។ ឧទាហរណ៍មួយទៀត គឺថាសហគមន៍ប្រហែលជាអាច ស្នើសុំឲ្យមានការជួយគាំទ្រដើម្បីពង្រឹងជំនាញនិងសមត្ថភាពរបស់ខ្លួន មុនពេលដែលពួកគេអាចមានលទ្ធភាពក្នុងការកំណត់និងអភិវឌ្ឍន៍យុទ្ធសាស្ត្រតស៊ូមតិ ដើម្បីសម្រេចវត្ថុបំណងរបស់ពួកគេបាន។

ឧបករណ៍នេះ ផ្តល់នូវមគ្គុទេសក៍ណែនាំ និងព័ត៌មានស្តីពីសកម្មភាព និងឧបករណ៍នានាដែលត្រូវបានប្រើប្រាស់ ដោយអង្គការសិទ្ធិផែនដី (EarthRights) និងដៃគូនានាក្នុងការគាំទ្រដើម្បីសម្រេចនូវគោលដៅរបស់សហគមន៍ ដោយរួមបញ្ចូលទាំងការបណ្តុះបណ្តាល សិក្ខាសាលា ការកសាងបណ្តាញ និងកិច្ចសហការបែបយុទ្ធសាស្ត្រ ព្រមទាំងការចូលរួមក្នុងដំណើរការ និងសកម្មភាពតស៊ូមតិ។ សកម្មភាពទាំងអស់នេះ ឆ្លុះបញ្ចាំងអំពីវិធីសាស្ត្រដែលសហគមន៍ គឺជាចំនុចស្នូលក្នុងឧបករណ៍ LEAD។ វាមានលក្ខណៈជាក់លាក់តាមបរិបទ អាចសម្របទៅតាមបរិបទបាន ហើយអាចបង្កើតជាយុទ្ធសាស្ត្រធ្វើយុទ្ធនាការមួយដែលដឹកនាំដោយសហគមន៍។

## ២.១ ឧបករណ៍ដែលជាធាតុផ្សំរបស់ LEAD

នៅក្នុងសំណុំឧបករណ៍ នេះមានឧបករណ៍ផ្សេងទៀត ដែលជាធាតុរបស់ LEAD។ ឧបករណ៍ទាំងអស់នេះ គឺជាសកម្មភាពដែលកាន់តែមានរចនាសម្ព័ន្ធជាក់លាក់និងជាផ្លូវការ។ ឧបករណ៍ទាំងនេះ រួមមានឧបករណ៍ដែលតាក់តែងឡើងដោយ អង្គការសិទ្ធិផែនដី (ការរចនាឧបករណ៍ដោះស្រាយបណ្តឹង ដែលដឹកនាំដំណើរការដោយសហគមន៍) ក៏ដូចជាឧបករណ៍ដែលតាក់តែងឡើងដោយអ្នកផ្សេងទៀត ប៉ុន្តែត្រូវបានយកមកប្រើប្រាស់ដោយ អង្គការសិទ្ធិផែនដី។ ឧបករណ៍ថ្មីៗអាចនឹងត្រូវបញ្ចូលបន្ថែមទៀតក្នុងពេលអនាគត ប៉ុន្តែនាពេលបច្ចុប្បន្ន រួមមាន៖

- ការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍
- ការវាយតម្លៃហេតុប៉ះពាល់សុខភាពរបស់សហគមន៍
- ការចូលរួមនៅក្នុងដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- ការរចនាយន្តការប្រព្រឹត្តទៅនៃការដោះស្រាយវិវាទដែលដឹកនាំប្រតិបត្តិដោយសហគមន៍

**ការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍ (CNRM)** គឺជាឧបករណ៍ប្រមូលព័ត៌មានសម្រាប់សហគមន៍ដើម្បីកត់ត្រាជាឯកសារអំពីបញ្ហាមួយចំនួនរួមមាន បរិស្ថាន មនុស្ស សង្គម និងវប្បធម៌ជាដើម។ សមាជិកសហគមន៍ត្រូវបានបណ្តុះបណ្តាល អំពីសកម្មភាពនានា ពួកគេដឹកនាំក្នុងការប្រមូលផលប៉ះពាល់ទាំងនោះដោយខ្លួនឯង។ ឧបករណ៍នេះអាចរួមបញ្ចូល ការកត់ត្រាជាឯកសារអំពីប្រភពទឹក ផ្ទៃដីកសិកម្ម សេដ្ឋកិច្ចក្នុងមូលដ្ឋាន ផ្នែកវប្បធម៌និងសារៈសំខាន់នៃប្រវត្តិនៃការប្រើប្រាស់ដី និងធនធាននានា។ ការចងក្រងជាឯកសារនេះ ជួយបង្កើននូវចំណេះដឹង អំពីសុក្រឹតភាពនៃដីនិងគុណតម្លៃពិតប្រាកដរបស់ដី និងដែលអាចផ្ទៀងផ្ទាត់បានព្រមទាំងជួយដល់សហគមន៍ ក្នុងការស្វែងយល់អំពីគុណតម្លៃនៃធនធានធម្មជាតិដែលស្ថិតនៅក្នុងតំបន់របស់ពួកគេ។ ឧបករណ៍នេះផ្តល់នូវព័ត៌មានដើមគ្រាដែលអាចមានប្រយោជន៍ក្នុងការតស៊ូមតិក្នុងពេលអនាគត។

**ការវាយតម្លៃហេតុប៉ះពាល់សុខភាពរបស់សហគមន៍ (CHIA)** គឺជាឧបករណ៍សម្រាប់ប្រមូលព័ត៌មានមួយផ្សេងទៀតដែលជួយសហគមន៍ក្នុងការកត់ត្រា ចងក្រងជាឯកសារអំពីផលប៉ះពាល់ដែលអាចកើតមានឡើង ដោយសារគម្រោងណាមួយក្នុងសហគមន៍របស់ពួកគេ។ សមាជិកសហគមន៍ត្រូវបានបណ្តុះបណ្តាលអំពីសកម្មភាពនានា ហើយដឹកនាំក្នុងការកំណត់ និងចងក្រងអំពីផលប៉ះពាល់ ឬផលប៉ះពាល់ នៃគម្រោងណាមួយដែលអាចកើតមានឡើងទៅលើធនធានធម្មជាតិ សេដ្ឋកិច្ច សុខភាព វប្បធម៌ និងបេតិកភណ្ឌប្រវត្តិសាស្ត្រ។ សកម្មភាពមួយចំនួនមានភាពដូចគ្នាទៅនឹងការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍។ ការប្រើប្រាស់ពាក្យ «សុខភាព» នេះ សំដៅទៅលើសុខភាពទាំងស្រុងរបស់សហគមន៍ ដោយរួមបញ្ចូលទាំងកត្តាជាច្រើនដែលអាចទទួលរងផលប៉ះពាល់ដែលកើតចេញមកពីការអនុវត្តអំពីគម្រោង។ ព័ត៌មានដែលប្រមូលបាន អាចមានប្រយោជន៍ នៅពេលចូលរួមក្នុងដំណើរការតស៊ូមតិ និង/ឬ ការស្វែងរកដំណោះស្រាយ។

**ការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)** គឺជាឧបករណ៍សម្រាប់ ការចូលរួមក្នុងដំណើរការ និងការតស៊ូមតិ ដើម្បីបំពាក់បំប៉នដល់សហគមន៍ក្នុងការធ្វើអោយមានការជះឥទ្ធិពលទៅលើគម្រោងអភិវឌ្ឍន៍ណាមួយ ឬ ក្នុងការស្វែងរកការបញ្ឈប់គម្រោងនោះ ប្រសិនបើផលប៉ះពាល់ដែលបង្កគ្រោះថ្នាក់ មិនអាចដោះស្រាយបាន។ ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននេះគឺ វាយតម្លៃទៅលើផលប៉ះពាល់នៃគម្រោងមួយ ហើយដំណើរការនេះត្រូវតែបំពេញឲ្យចប់សព្វគ្រប់ មុនពេលដែលគម្រោងណាមួយត្រូវ បានអនុម័ត។ ប្រទេសនីមួយៗ មានច្បាប់ផ្សេងៗគ្នាដែលចែងអំពីលក្ខខណ្ឌតម្រូវឲ្យមានការចូលរួមជាសាធារណៈ។ ប៉ុន្តែជាទូទៅ នៅគ្រប់ដំណាក់កាលផ្សេងគ្នានៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ គួរតែមានឱកាស សម្រាប់សហគមន៍ដែលអាចទទួលរងផលប៉ះពាល់ និងសង្គមស៊ីវិល ក្នុងការធ្វើការអន្តរាគមន៍ ការលើកឡើងនូវក្តីបារម្ភ និងស្នើឡើងនូវដំណោះស្រាយ ឬការផ្លាស់ប្តូរមួយចំនួនចំពោះគម្រោងទាំងនោះ។ ប្រសិនបើសហគមន៍ជ្រើសរើសក្នុងការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឧបករណ៍នេះនឹងផ្តល់ជូនពួកគាត់នូវមគ្គទេសក៍ដ៏ចាំបាច់មួយ។

**ការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM)** គឺជាឧបករណ៍ដែលទើបលេចឡើងថ្មីមួយ សម្រាប់ចូលរួមក្នុងដំណើរការ នៃការដោះស្រាយផលប៉ះពាល់ដែលកើតឡើងចេញពីគម្រោងនោះ តាមរយៈការអះអាង និងការតស៊ូមតិ ទាមទារឲ្យមានយន្តការដោះស្រាយផលប៉ះពាល់នៅក្នុងមូលដ្ឋានតាមការចង់បានរបស់ខ្លួន។ យោងតាមគោលការណ៍ណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស យន្តការដោះស្រាយផលប៉ះពាល់នៅក្នុងសហគមន៍មូលដ្ឋាននឹងត្រូវបានបង្កើតឡើង ឬនឹងត្រូវចូលរួមនៅក្នុងដំណើរការនៃការដោះស្រាយបញ្ហា ដោយអ្នកវិនិយោគ នាទីកន្លែងដែលក្រុមហ៊ុននោះបានធ្វើសកម្មភាពធុរកិច្ច។ ដំណើរការទាំងនោះ ជារឿយៗគេហៅថា យន្តការតវ៉ាកម្រិតប្រតិបត្តិការ (OGMs)។ OGMs គឺជាយន្តការដែលបង្កើតឡើង និងប្រតិបត្តិដោយក្រុមហ៊ុន ប៉ុន្តែនៅក្នុង CD-OGM សហគមន៍ជាអ្នកដឹកនាំដំណើរការនៃការរចនា តាមរយៈការពន្យល់អំពីដំណើរការនៃការដោះស្រាយវិវាទដែលពួកគេចង់បាន តើផលប៉ះពាល់ប្រភេទណាគួរតែត្រូវបានដោះស្រាយ និងប្រភេទនៃដំណោះស្រាយដែលគួរតែត្រូវបានផ្តល់ឲ្យ និងស្នើឡើងឲ្យក្រុមហ៊ុនចូលរួម នៅក្នុងដំណើរការនេះ ដូច OGM ដែរ។ ជំនួសមកវិញ សហគមន៍អាចស្វែងរកការដំណើរការនៃការដោះស្រាយវិវាទ ដោយមានកិច្ចសហការ ជាមួយក្រុមហ៊ុនបាន។

# ២.២ ការកសាងជំនឿទុកចិត្ត




ការកសាងនិងការរក្សាជំនឿទុកចិត្ត គឺមានសារៈសំខាន់ខ្លាំងនិងមានភាពជាក់លាក់ទៅតាមបរិបទនីមួយៗ។ វាអាស្រ័យទៅលើថាតើ ដៃគូនោះមានទំនាក់ទំនងរួចជាស្រេចជាមួយសហគមន៍ហើយឬនៅ អាស្រ័យទៅលើការយល់ឃើញ និងបទពិសោធន៍កាលពីមុនអំពីដៃគូរបស់សហគមន៍ (ជាពិសេសជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល) អាស្រ័យទៅលើ ភាពស៊ីសង្វាក់គ្នានិងបញ្ហាក្នុងការអនុវត្តជាក់ស្តែង ក៏ដូចជាការដឹងអំពីបរិយាកាសនយោបាយ។ ការកសាងជំនឿទុកចិត្ត ទាមទារឲ្យមានការទាក់ទងគ្នាទៅវិញទៅមក ភាពស្មោះត្រង់ និងការគោរពអោយតម្លៃគ្នា។ ការបង្កើតនិងការរក្សាជំនឿទុកចិត្ត ត្រូវការពេលវេលាហើយជាដំណើរការបន្តជាប់ជានិច្ចឥតដាច់។

- ជៀសវាងការអនុវត្តដែលគិតតែទាញយកប្រយោជន៍និងត្រូវបង្ហាញការគោរព សូមរក្សាអោយបាននូវគុណតម្លៃស្នូល និងសូមចងចាំអំពីតួនាទីស្នូលរបស់សហគមន៍។ ត្រូវបង្ហាញតាមរយៈសកម្មភាពរបស់អ្នក ថាតួនាទីរបស់អ្នកគឺដើម្បីគាំទ្រ បង្ហាញថាចំណេះដឹងមូលដ្ឋាននិងភាពជាម្ចាស់ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ និងបង្ហាញថា គោលបំណងនៃភាពជាដៃគូនេះ គឺដើម្បីផលប្រយោជន៍របស់សហគមន៍។
- ភាពស្មោះត្រង់និងតម្លាភាព សូមចងចាំឲ្យច្បាស់អំពីតួនាទីរបស់អ្នក អំពីដែនកំណត់ទៅលើយុទ្ធសាស្ត្រឬសកម្មភាពនីមួយៗ ព្រមទាំងហានិភ័យដែលមានជាប់ពាក់ព័ន្ធ។ វាជាការសំខាន់ដែលត្រូវយល់អំពីការរំពឹងទុករបស់ពួកគេ និងត្រូវបញ្ជាក់ឲ្យច្បាស់អំពីទំនាក់ទំនងរបស់អ្នក។
- ការចំណាយពេលវេលាជាមួយសហគមន៍ដែលអ្នកកំពុងគាំទ្រ គឺជាវិធីដ៏សំខាន់មួយដើម្បីកសាងទំនាក់ទំនងដ៏រឹងមាំមួយ។ វាក៏ជួយឲ្យអ្នកយល់អំពីសហគមន៍និងគម្រោងនោះដែរ។

- **ការបង្ហាញអំពីការប្តេជ្ញាចិត្ត** បើទោះបីជាដៃគូណាមួយមិនអាចស្ថិតនៅក្នុងសហគមន៍ ឬទោះបីជាសហគមន៍ មិនចង់ឲ្យដៃគូនោះស្ថិតនៅក្នុងសហគមន៍ក៏ដោយ ក៏នៅមានវិធីផ្សេងៗជាច្រើនទៀតសម្រាប់ឲ្យដៃគូបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើការជាមួយសហគមន៍។ ការរក្សាការប្រាស្រ័យទាក់ទងគ្នា ការរាយការណ៍ត្រឡប់ទៅវិញអំពីព័ត៌មានដែលសហគមន៍អាចនឹងត្រូវការ ព្រមទាំងការអនុវត្តទៅតាមការប្តេជ្ញាចិត្តឬការសន្យាដែលបានលើកឡើង នឹងជួយក្នុងការបង្ហាញដល់សហគមន៍ថា ដៃគូមានការប្តេជ្ញាចិត្តក្នុងការគាំទ្រពួកគេក្នុងនាមជាសម្ព័ន្ធមិត្ត។

## ២.៣. ការកសាងសហគមន៍




### ២.៣.១ ការប្រមូលព័ត៌មាននិងការស្រាវជ្រាវបែបសហការ

នៅក្នុងស្ថានភាពជាច្រើន សហគមន៍អាចមិនបានដឹងថាគម្រោងអភិវឌ្ឍត្រូវបានរៀបចំ ឡើងនៅក្នុងតំបន់របស់ពួកគេទេ។ ប្រសិនបើពួកគេដឹងអំពីគម្រោង ក៏ប្រហែលជាមិនមានអ្នកណាប្រាប់ថានឹងមានរឿងអ្វីកើតឡើង ហើយវានឹងប៉ះពាល់ដល់ពួកគាត់ដោយរបៀបណានោះដែរ។ ប្រហែលជាគ្មាននរណាប្រាប់ពួកគេទាល់តែសោះ ឬពួកគេត្រូវបានផ្តល់ឲ្យនូវព័ត៌មានត្រឹមតែផ្នែកខ្លះ ឬពេលខ្លះពួកគេត្រូវបានផ្តល់ព័ត៌មានមិនត្រឹមត្រូវ ក្នុងគោលបំណងដើម្បីរុញឲ្យគម្រោងនោះដើរទៅមុខ។ ការទទួលបានព័ត៌មាន គឺជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សដ៏សំខាន់បំផុតមួយ ប៉ុន្តែជានិច្ចកាលតែងតែមានការពិបាកក្នុងការទទួលបានវា។ ការទទួលបានព័ត៌មាន នៅតែមានការលំបាកសម្រាប់សហគមន៍មូលដ្ឋាន ដែលកំពុងតែប្រឈមនឹងផលប៉ះពាល់ដោយសកម្មភាពធុរកិច្ចនិងគម្រោងអភិវឌ្ឍន៍។ ការធ្វើការស្រាវជ្រាវនិងសកម្មភាពប្រមូលព័ត៌មានតាមបែបសហការជាមួយសហគមន៍ អាចមិនត្រឹមតែជួយដល់សហគមន៍ក្នុងការប្រមូលព័ត៌មានដែលចាំបាច់នោះទេ ប៉ុន្តែដំណើរការនេះជារឿយៗតែងតែជួយបង្កើនចំណាប់អារម្មណ៍ ទំនុកចិត្ត និងភាពជាអ្នកដឹកនាំរបស់សហគមន៍ទៀតផង។

## ▪ ទស្សនៈកិច្ចសិក្សា

ទស្សនៈកិច្ចសិក្សា ជាវិធីសាស្ត្រមួយដែលមានប្រសិទ្ធភាពក្នុងការជួយសហគមន៍ឲ្យបានយល់អំពីផលប៉ះពាល់ដែលអាចកើតឡើង នៃគម្រោងមួយនោះ គឺការបានមើលឃើញនូវផលប៉ះពាល់នៃគម្រោងដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានោះជាមុនសិន។ នៅពេលដែលម្ចាស់គម្រោងនិយាយជាមួយនឹងសហគមន៍អំពីគម្រោងណាមួយ ជារឿយៗ ម្ចាស់គម្រោង និយាយក្នុងរបៀបដែលគម្រោងមិនសូវមានផលប៉ះពាល់ដូចដែលវាកើតឡើងពិតប្រាកដនោះទេ។ សហគមន៍អាចមានការលំបាកក្នុងការស្រមៃទៅដល់ទំហំនៃផលប៉ះពាល់ដែលរៀបរាប់នៅក្នុងឯកសារនានា ដូចជា ឯកសាររបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាដើម។

ទស្សនៈកិច្ចសិក្សាក៏អាចបង្កើតនូវឱកាសជាច្រើន សម្រាប់កសាងសាមគ្គីភាពនិងការកសាងបណ្តាញ ក្នុងសហគមន៍ ដែលអាចនឹងជួបបញ្ហាប្រឈមនិងផលប៉ះពាល់ស្រដៀងគ្នា។

## ▪ សកម្មភាពការធ្វើផែនទី

ការធ្វើផែនទីមានសារៈប្រយោជន៍ខ្លាំងណាស់ក្នុងការកសាងសហគមន៍ តាមរយៈការកំណត់ និងការចងក្រងឯកសារ ព័ត៌មានដែលពាក់ព័ន្ធ ព្រមទាំងផ្តល់នូវលំហមួយសម្រាប់កិច្ចសហការ និងការចូលរួមរបស់សហគមន៍។ សកម្មភាពធ្វើផែនទីជួយៈ

- បង្ហាញច្បាស់នូវ សុក្រឹតភាព និងគុណតម្លៃ ដែលកើតចេញអំពីទស្សនៈរបស់សហគមន៍។ ការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍ (CNRM) រួមបញ្ចូលទាំង ការប្រមូលព័ត៌មាននិងការចងក្រងជាឯកសារដែលមានលក្ខណៈបរិយាប័ន្ននិងតាមបែបសហការ ដែលជួយសហគមន៍ក្នុងការអភិវឌ្ឍ និងពង្រឹងទំនុកចិត្ត ព្រមទាំងជំនាញក្នុងភាពជាអ្នកដឹកនាំ។ តាមរយៈការធ្វើផែនទីធនធានធម្មជាតិនេះ សហគមន៍អាចកំណត់បាននិង លើកឡើងនូវគុណតម្លៃនៃការប្រើប្រាស់ដីរបស់ខ្លួនបាន។ ការណ៍នេះ អាចបង្កើនញាណនៃសេចក្តីថ្លៃថ្នូរ នឹងបង្កើតនូវការយល់កាន់តែប្រសើរអំពីរបៀបដែលមនុស្សគ្រប់គ្នា បានរួមចំណែកក្នុងការផ្តល់គុណតម្លៃដល់សហគមន៍របស់ពួកគេ។

- កំណត់ឲ្យបាននូវវិសាលភាពកាន់តែ សុក្រឹតអំពីផលប៉ះពាល់ដែលអាចកើតចេញពីគម្រោងនោះ។ ស្រដៀងគ្នានេះដែរ ការវាយតម្លៃហេតុប៉ះពាល់សុខភាពរបស់សហគមន៍ (CHIA) មានលក្ខណៈស្រដៀងគ្នាទៅនឹងការប្រមូលព័ត៌មាន និងការចងក្រងឯកសារដែលមានលក្ខណៈបរិយាប័ន្ន និងប្រកបដោយការសហការដែរ គឺមានគោលដៅក្នុងការអភិវឌ្ឍនិងការពង្រឹងទំនុកចិត្តព្រមទាំងជំនាញក្នុងភាពជាអ្នកដឹកនាំសហគមន៍។ ការប៉ាន់ប្រមាណបែបនេះ អាចជួយជំរុញឲ្យមានការឯកភាពគ្នានៅក្នុងសហគមន៍ តាមរយៈការបង្កើតនូវការយល់ដឹងប្រហាក់ប្រហែលគ្នា នូវ ផលប៉ះពាល់អវិជ្ជមាននៃគម្រោងទៅលើសហគមន៍ ព្រមទាំង ការលើកកម្ពស់សេចក្តីថ្លៃថ្នូររបស់សហគមន៍ តាមរយៈការកសាងភស្តុតាងរឹងមាំសម្រាប់ការតស៊ូមតិ ដែលដឹកនាំដោយសហគមន៍។

- កំណត់តួអង្គពាក់ព័ន្ធនៅក្នុងគម្រោង ការធ្វើការសិក្សាវាយតម្លៃអំពីកម្រិតនៃអំណាចរបស់ពួកគេ ព្រមទាំងអំពីជំហរក្នុងការគាំទ្រ ឬក្នុងការជំទាស់។ ការធ្វើការវិភាគតួអង្គ ឬភាគីពាក់ព័ន្ធនិងការវិភាគអំពីអំណាច គឺជាយុទ្ធសាស្ត្រយុទ្ធនាការនិងការតស៊ូមតិ ដែលតែងធ្វើជាទូទៅនិងដែលមានប្រសិទ្ធភាព។

- ការកំណត់អំពីកាតព្វកិច្ចតាមផ្លូវច្បាប់ ការប្តេជ្ញាចិត្ត និង ឥទ្ធិពលនៃឱកាស ជាមួយតួអង្គ ក៏ដូចជា យុទ្ធសាស្ត្រតាមផ្លូវច្បាប់និងពាក់កណ្តាលផ្លូវច្បាប់ដែលមានស្រាប់។ ការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍(CD-OGM) រួមបញ្ចូលទាំងសកម្មភាពដែលមានលក្ខណៈបរិយាប័ន្ន និងលក្ខណៈសហការគ្នា រាប់បញ្ចូលទាំងដំណើរការនៃការប្រមូលធាតុចូល ដំណើរការត្រួតពិនិត្យ និងដំណើរការនៃការអនុវត្ត ចេញមកពីមនុស្សគ្រប់គ្នានៅក្នុងសហគមន៍។ ការធ្វើបែបនេះ នឹងជួយអភិវឌ្ឍនិងពង្រឹងទំនុកចិត្ត និងជំនាញក្នុងភាពជាអ្នកដឹកនាំ។ ភាពជោគជ័យនៅក្នុងការរចនានិង/ឬអនុវត្ត ការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM) អាចបង្កើនញាណនៃភាពថ្លៃថ្នូរ ទំនុកចិត្ត និងឯកភាពគ្នារបស់សហគមន៍។

## ២.៣.២ វគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា

សហគមន៍ គឺជាប្រភពចំណេះដឹងដ៏សំខាន់ ប៉ុន្តែពួកគេប្រហែលជាមិនទទួលបានចំណេះដឹងនិងព័ត៌មានដែលនឹងជួយពួកគេឲ្យយល់កាន់តែច្បាស់អំពីគម្រោង យល់អំពីសិទ្ធិ និងយល់អំពីរបៀបចូលរួម ក្នុងការការពារសិទ្ធិរបស់ពួកគេឲ្យកាន់តែប្រសើរនោះទេ។ ការបណ្តុះបណ្តាលផ្តល់ឱកាសសម្រាប់ប្រជាសហគមន៍ ក្នុងការអភិវឌ្ឍនិងកំណត់អោយឃើញនូវចំណេះដឹងនិងជំនាញដែលចាំបាច់ដើម្បីអភិវឌ្ឍនិងអនុវត្តយុទ្ធសាស្ត្រទាំងឡាយឲ្យមានប្រសិទ្ធភាព។ មានប្រភេទនៃការបណ្តុះបណ្តាលផ្សេងៗគ្នា ដែលអាចមានប្រយោជន៍ រួមមាន៖

- ផ្តោតលើជំនាញនិងចំណេះដឹង៖ ការបណ្តុះបណ្តាលបែបនេះ មានលក្ខណៈជាក់លាក់ទៅតាមបរិបទនីមួយៗ ហើយអាចបញ្ចូលការបណ្តុះបណ្តាលអំពីរបៀបចូលរួមនៅក្នុងសកម្មភាពធ្វើផែនទីដូចដែលបានពិភាក្សាខាងលើ អំពីការអភិវឌ្ឍជំនាញចរចា និងជំនាញនិយាយជាសាធារណៈ ឬបញ្ហាបច្ចេកទេសផ្សេងៗទៀត។
- ផ្តោតលើសិទ្ធិ៖ ការបណ្តុះបណ្តាលបែបនេះជួយសហគមន៍ឲ្យយល់អំពីយន្តការការពារសិទ្ធិនៅក្នុងប្រទេស នៅថ្នាក់តំបន់ និងនៅកម្រិតអន្តរជាតិ ដែលពួកគេមាននិងអាចស្វែងរកការការពារសិទ្ធិទាំងនោះបាន។
- ផ្តោតច្បាប់៖ ការបណ្តុះបណ្តាលបែបនេះ ជួយសហគមន៍ឲ្យយល់អំពីច្បាប់ក្នុងប្រទេស ច្បាប់តំបន់ ឬច្បាប់អន្តរជាតិ ដែលជាប់ទាក់ទងទៅនឹងសហគមន៍និងគម្រោងរបស់ពួកគេ។
- ល្ខោនជីវិត៖ ជាវិធីសាស្ត្រមួយសម្រាប់គៀរគឲ្យមានការចូលរួមពីសហគមន៍និងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល ។
- ការចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)៖ ការបណ្តុះបណ្តាលនេះ អាចជួយឲ្យសហគមន៍យល់អំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងអំពីរបៀបចូលរួមឲ្យមានប្រសិទ្ធភាព ប្រសិនបើពួកគេ សម្រេចចិត្តចូលរួម។

## ២.៣.៣ ការគាំទ្រការប្រាស្រ័យទាក់ទងនៅក្នុងសហគមន៍

មានចំណុចខ្លាំងមួយចំនួនទាក់ទងទៅនឹងទិន្ន័យ ព្រមទាំងចំណុចខ្លាំងមួយចំនួនទៀតដែលទាក់ទងទៅនឹងព័ត៌មាននិងចំណេះដឹង។ កាលណាសហគមន៍មានព័ត៌មានកាន់តែច្រើន ហើយកាលណាពួកគេ ប្រាស្រ័យទាក់ទងគ្នានិងកិច្ចសហប្រតិបត្តិការជាមួយគ្នាទៅវិញទៅមកកាន់តែខ្លាំង នោះពួកគេកាន់តែមានភាពរឹងមាំក្នុងការសម្រេចចិត្ត ហើយនិងកាន់តែដែលមានឥទ្ធិពលខ្លាំងក្នុងការចរចាណាក៏ដោយ។

វិធីសាស្ត្រប្រាស្រ័យទាក់ទងដែលមានលក្ខណៈបរិយាប័ន្ន នឹងធានាថា សំឡេងដែលជានិច្ចកាលត្រូវបានគេផាត់ចោលនឹងត្រូវបានគេស្តាប់ឮឡើងវិញ។ ការធ្វើបែបនេះ អាចជួយបណ្តុះនូវបរិយាកាសមួយដែលកាន់តែមានភាពស្អិតរមួត។ បន្ទាប់មក បរិយាកាសដែលកាន់តែមានភាពស្អិតរមួត អាចបង្កើតនូវសហគមន៍មួយ កាន់តែរឹងមាំ។

សហគមន៍នីមួយៗមានរបៀបក្នុងការ ចងក្រងនិងយុទ្ធសាស្ត្រក្នុងការប្រាស្រ័យទាក់ទងតាមលក្ខណៈផ្សេងៗគ្នា។ សកម្មភាពដែលមានប្រយោជន៍មួយចំនួន អាចរួមបញ្ចូលដូចជា៖

- ការប្រជុំទៀងទាត់ ទោះជាផ្លូវការឬក្រៅផ្លូវការក៏ដោយ
- ការសង្ខេបរំលឹកឡើងវិញនិងការឆ្លុះបញ្ចាំង
- ការពិនិត្យតាមដានជាទៀងទាត់
- មានក្រុមការងារជាក់លាក់



# ២.៤. ការរៀបចំយុទ្ធនាការ




តួនាទីដែលដៃគូគាំទ្រនឹងត្រូវធ្វើ គឺការរៀបចំកសាងយុទ្ធនាការមួយ ដែលមានលក្ខណៈជាក់លាក់តាមបរិបទនីមួយៗ អាស្រ័យទៅលើតម្រូវការនិងការចង់បានរបស់សហគមន៍។ ការគាំទ្រអាចមានលក្ខណៈបើកចំហជាសាធារណៈ ឬគាំទ្រពីក្រោយ ហើយដៃគូគាំទ្រ អាចជាដៃគូតែមួយគត់ ឬជាដៃគូមួយក្នុងចំណោមបណ្តាញ ណាមួយ។

## ២.៤.១ សកម្មភាពតស៊ូមតិ

សកម្មភាពតស៊ូមតិ សំដៅទៅលើសកម្មភាពទូលំទូលាយជាច្រើនដែលអាច នាំឲ្យមានការចាប់អារម្មណ៍កាន់តែច្រើនទៅលើបញ្ហានានាដែលសហគមន៍កំពុងតែជួបប្រទះ ក្នុងគោលបំណងដើម្បីទទួលបានការគាំទ្របន្ថែម។ សកម្មភាពតស៊ូមតិ អាចមានចាប់តាំងពី សកម្មភាពទន់ភ្លន់ ជាការផ្តល់ព័ត៌មានរហូតដល់ការប្រឈមមុខដាក់គ្នា ដោយអាស្រ័យទៅលើគោលបំណងរបស់សហគមន៍ កំលាំង កត្តាសន្តិសុខសុវត្ថិភាព។ ឧទាហរណ៍នៃសកម្មភាពតស៊ូមតិរួមមានដូចជា៖

- ការនិយាយនៅក្នុងព្រឹត្តិការណ៍សាធារណៈ
- ការបង្ហាញអំពីភ័ស្តុតាងនិងរបកគំហើញនៃការស្រាវជ្រាវ ដោយរួមបញ្ចូលទាំងសម្ភារៈដែលផលិតឡើង តាមរយៈការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍ និងការវាយតម្លៃហេតុប៉ះពាល់ទៅលើសុខភាពសហគមន៍
- ការចូលរួមក្នុងសកម្មភាពបណ្តាញឬការសហការនានា
- ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមវិធីផ្សេងៗគ្នា រួមបញ្ចូលទាំងការរៀបចំសន្និសីទសារព័ត៌មាន ការអញ្ជើញអ្នកសារព័ត៌មានធ្វើទស្សនកិច្ច និងសិក្សាអំពីស្ថានភាពសហគមន៍ ព្រមទាំងការធ្វើការជាមួយនឹងអ្នកផលិតភាពយន្ត ដើម្បីផលិតជាឯកសារ និងចែករំលែករឿងរ៉ាវរបស់សហគមន៍

- សកម្មភាពដោយផ្ទាល់ រួមបញ្ចូលទាំងការជំទាស់តវ៉ា ការធ្វើបាតុកម្ម និងព្រឹត្តិការណ៍សហគមន៍
- ការបញ្ជូនលិខិតនិង/ឬសម្ភារៈនានាដោយផ្ទាល់ ដើម្បីធ្វើអោយជះឥទ្ធិពលទៅលើការផ្លាស់ប្តូរការសម្រេចចិត្តនៅកម្រិតក្រុមហ៊ុន ឬកម្រិតរដ្ឋាភិបាល

## ២.៤.២ កិច្ចសហការជាមួយដៃគូនិងបណ្តាញ

ទោះបីជាសហគមន៍គឺជាតួអង្គសំខាន់ក្នុងការធ្វើយុទ្ធនាការឲ្យបានជោគជ័យក៏ដោយ ក៏ការធ្វើការជាមួយដៃគូនិងបណ្តាញ អាចជួយពួកគេធ្វើឲ្យវាកាន់តែរឹងមាំដែរ។ ក្រុមទាំងនេះអាចស្វែងរកបាននូវអ្នកជំនាញជាក់លាក់ណាមួយ អាចនាំរឿងរ៉ាវរបស់សហគមន៍ឲ្យ ក្រុមមនុស្សផ្សេងទៀតបានដឹងកាន់តែទូលាយ ព្រមទាំងអាចផ្តល់ឱកាសក្នុងការចែករំលែកនូវយុទ្ធសាស្ត្រនិងគំនិត។ ភាពជាដៃគូទាំងនេះ អាចកើតមានរវាងសហគមន៍ផ្សេងគ្នា ដែលអាចកំពុង ប្រឈមនឹងបញ្ហាស្រដៀងគ្នា ឬជាមួយក្រុមផ្សេងទៀតនៅក្នុងសហគមន៍តែមួយ។ វាអាចរាប់បញ្ចូលទាំងការធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្រុមអ្នកសិក្សាធិការ ក្រុមអ្នកគិត ស្ថាប័នឯកជន និងក្រុមផ្សេងទៀត។

ជាការសំខាន់ណាស់ដែលដៃគូនិងបណ្តាញទាំងអស់នេះ មិនព្យាយាមចូលជ្រៀតជ្រែក ទៅក្នុងការធ្វើការសម្រេចចិត្ត ឬទាញយកភាពជាអ្នកដឹកនាំចេញពីសហគមន៍ ប៉ុន្តែត្រូវធ្វើការ ដោយសាមគ្គីភាពពិតប្រាកដជាមួយសហគមន៍។

## ២.៤.៣ ការចូលរួម ជាមួយតួអង្គដែលពាក់ព័ន្ធនឹងគម្រោង

សហគមន៍ ប្រហែលជាចង់ឬប្រហែលមិនចង់ចូលរួមពាក់ព័ន្ធដោយផ្ទាល់ជាមួយតួអង្គផ្សេងទៀតដែលពាក់ព័ន្ធនឹងគម្រោង ដោយសារហេតុផលមួយចំនួន។ អាស្រ័យទៅតាមបរិបទ កម្រិតសមត្ថភាពរបស់ពួកគេក្នុងការចូលរួម ក៏មានភាពខុសប្លែកពីគ្នាដែរ។ ការចូលរួមក្នុងដំណើរការនេះ អាចមានលក្ខណៈជាផ្លូវការឬក្រៅផ្លូវការ ហើយអាចមានលក្ខណៈសហការ ឬប្រឈមមុខដាក់គ្នា។ ប្រការនេះ អាស្រ័យទៅលើគោលដៅរបស់សហគមន៍ កំលាំងដែលពួកគេមាន ហានិភ័យទាក់ទងនឹងសន្តិសុខសុវត្ថិភាព និងកត្តានានាដែលទាក់ទងជាមួយនឹងបរិបទ។ ការចូលរួមពាក់ព័ន្ធក្នុងដំណើរការ អាចមានជាទម្រង់ផ្សេងគ្នា និងអាចមានដូចជា៖

- ការប្រជុំផ្ទាល់ជាមួយភាគីពាក់ព័ន្ធនឹងគម្រោង
- ការចែករំលែកលទ្ធផលការស្រាវជ្រាវនិងការវិភាគ ទាក់ទងនឹងគម្រោង ដូចជា សម្ភារៈដែលបានផលិតតាមរយៈការធ្វើផែនទីធនធានធម្មជាតិរបស់សហគមន៍ (CNRM) និងការវាយតម្លៃហេតុប៉ះពាល់សុខភាពរបស់សហគមន៍ (CHIA)
- ការចូលរួមនៅក្នុងការពិគ្រោះយោបល់ជាផ្លូវការ សកម្មភាពភាគីពាក់ព័ន្ធផ្សេងទៀត ការតាមដានសកម្មភាពសហគមន៍ ឬការចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)

ការចូលរួមក្នុងដំណើរការនេះ អាចត្រូវបានប្រើទន្ទឹមគ្នានឹងយុទ្ធសាស្ត្រផ្សេងៗ។ ឧទាហរណ៍ លទ្ធផលនៃការស្រាវជ្រាវ និង ការវិភាគ អាចយកទៅប្រើក្នុងសកម្មភាពតស៊ូមតិ ដូចជាការបោះពុម្ពផ្សាយនូវការវិភាគការស្រាវជ្រាវ ឬការធ្វើសន្និសីទកាសែត នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាផ្លូវការណាមួយ។ ការចូលរួមក្នុងដំណើរកានេះ អាចត្រូវបានធ្វើឡើងរួមគ្នាជាមួយដៃគូ ឬ បណ្តាញផ្សេងទៀតក្នុងគោលបំណងដើម្បីចែកចាយព័ត៍ឲ្យបានទៅដល់ក្រុមមនុស្សកាន់តែទូលំទូលាយ។ ការចូលរួមជាមួយ តួអង្គពាក់ព័ន្ធនឹងគម្រោងអាចជាលក្ខខណ្ឌតម្រូវព្រោះវាជាចំណែកមួយនៃដំណើរការនៃ ការចូលរួមប្រកបដោយតម្លាភាព ឬក៏ជាយន្តការក្នុងការដោះស្រាយវិវាទ។

សហគមន៍ជានិច្ចការតែងតែអាចធ្វើការវាយតម្លៃឡើងវិញ អំពីរបៀបនៃការចូលរួមរបស់ពួកគេ។ ឧទាហរណ៍ ប្រសិនបើការប្រជុំដោយផ្ទាល់ និងសកម្មភាពស្វែងរកកិច្ចសហការ មិនមានប្រសិទ្ធភាពទេ ពួកគេអាចសម្រេចធ្វើ សកម្មភាពដោយផ្ទាល់ឬបង្កើនការផ្សព្វផ្សាយជាសាធារណៈ នៅខាងក្រៅឲ្យកាន់តែច្រើន។ ឬ ប្រសិនបើមានហានិភ័យផ្នែក សន្តិសុខសុវត្ថិភាពកើនឡើង សហគមន៍អាចផ្លាស់ប្តូរវិធីសាស្ត្រនៅក្នុងការចូលរួម ឬបញ្ឈប់ការ ចូលរួមទាំងស្រុងក៏ថាបាន។

## ២.៤.៤ ការចូលរួមក្នុងដំណើរការតាមផ្លូវយុត្តាធិការ និងពាក់កណ្តាលយុត្តាធិការ

ដំណើរការតាមផ្លូវយុត្តាធិការនិងពាក់កណ្តាលយុត្តាធិការនេះជារឿយៗ ត្រូវបានប្រើនៅពេលដែលស្វែងរកដំណោះស្រាយ សម្រាប់ភយន្តរាយដែលចេញពីគម្រោង។ គេក៏អាចប្រើវាដើម្បីស្វែងរកការបញ្ឈប់គម្រោងនោះ ជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ តែម្តងក៏បានដែរ។ ដំណើរការតាមផ្លូវយុត្តាធិការនិងពាក់កណ្តាលយុត្តាធិការនីមួយៗ មានអត្ថប្រយោជន៍និងបញ្ហាប្រឈមផ្សេងគ្នា។ ដំណើរការមួយចំនួន ងាយស្រួលក្នុងការធ្វើ ប៉ុន្តែប្រហែលជាមិនធានាអំពីលទ្ធផលនោះទេ ឬ មិនអាចយកទៅអនុវត្តបានតែម្តង។ យន្តការដែលរឹងមាំ ដូចជាតុលាការជាដើមនោះ អាចត្រូវការចំណាយពេលវេលាច្រើន ហើយត្រូវចំណាយប្រាក់កាសច្រើន។ ដំណើរការទាំងអស់នេះ ក៏អាចមានភាពខុសប្លែកពីគ្នា អាស្រ័យទៅតាមវិធីក្នុងការធ្វើប្រតិបត្តិការ និងលទ្ធផលដែលយើងចង់បានដែរ។ ដំណើរការទាំងអស់នេះ អាចផ្តោតទៅលើគណនេយ្យភាព ឬផ្តោតទៅលើការដោះស្រាយបញ្ហា។

សហគមន៍មួយអាចចង់ប្រើប្រាស់ដំណើរការតាមផ្លូវយុត្តាធិការនិងពាក់កណ្តាលយុត្តាធិការទន្ទឹមគ្នាជាមួយនឹងយុទ្ធសាស្ត្រផ្សេងទៀត។ ឧទាហរណ៍ ការទទួលបានការចាប់អារម្មណ៍ពីសាធារណៈជនឬប្រព័ន្ធផ្សព្វផ្សាយ នៅពេលដែលពាក្យបណ្តឹងណាមួយត្រូវបានដាក់ អាចដាក់សម្ពាធទៅលើតួអង្គនានា និង អាចបង្កើនការជះឥទ្ធិពលបន្ថែមទៀតពីសំណាក់សហគមន៍។ ក៏ប៉ុន្តែ ក្នុងស្ថានភាពមួយ ចំនួនទៀត ការដាក់បណ្តឹងមិនអាចធ្វើទៅបានទេ ប្រសិនបើសហគមន៍ កំពុងចូលរួមក្នុងដំណើរការតស៊ូមតិ ឬសិទ្ធិក្នុងការនិយាយជាសាធារណៈត្រូវបានដាក់កំហិត។ អាចមានហានិភ័យមួយចំនួនទាក់ទងជាមួយនឹងការសងសឹកក្រៅផ្លូវច្បាប់ ពីក្រុមហ៊ុន ឬពីរដ្ឋាភិបាល នៅពេលកំពុងចូលរួមក្នុងដំណើរការទាំងអស់នេះ ដូច្នេះហើយ គួរពិភាក្សាអំពីហានិភ័យផ្នែកសន្តិសុខ នៅពេលធ្វើការប៉ាន់ប្រមាណអំពីជម្រើសនានា។

សកម្មភាពធ្វើផែនទី វគ្គបណ្តុះបណ្តាល សិក្ខាសាលា អាចជួយអភិវឌ្ឍការយល់អំពីការការពារតាមផ្លូវច្បាប់និងអំពីបទដ្ឋានសិទ្ធិមនុស្សផ្សេងទៀតនៅក្នុងប្រទេស ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ព្រមទាំងយល់អំពី កាតព្វកិច្ចនិងការប្តេជ្ញាចិត្តរបស់តួអង្គពាក់ព័ន្ធនៅក្នុងគម្រោងនេះដែរ។ សកម្មភាពនេះអាចជួយសហគមន៍ឲ្យធ្វើការសម្រេចចិត្តបែបយុទ្ធសាស្ត្រ អំពីដំណើរការដែលអាចធ្វើទៅបាន និងដែលមានអត្ថប្រយោជន៍បំផុត។

ដំណើរការយុត្តាធិការនិងពាក់កណ្តាលយុត្តាធិការ រួមមានដូចជា៖

- ការប្តឹងទៅតុលាការ (ការប្តឹងផ្តល់)៖ អាស្រ័យទៅលើស្ថានភាពជាក់ស្តែង សហគមន៍ប្រហែលជាអាច ប្រើប្រាស់តុលាការ ឬសាលាជម្រះក្តីក្នុងស្រុក ឬតុលាការនៅក្នុងប្រទេសដែលក្រុមហ៊ុនតាំងនៅ។
- ការប្រើប្រាស់ស្ថាប័នសិទ្ធិមនុស្សក្នុងស្រុក ថ្នាក់តំបន់ ឬកម្រិតអន្តរជាតិ៖ អាស្រ័យតាមស្ថានភាពជាក់ស្តែង សហគមន៍ប្រហែលជាអាចប្រើប្រាស់គណៈកម្មាធិការសិទ្ធិមនុស្សថ្នាក់ជាតិ ឬការិយាល័យទទួលបណ្តឹងពលរដ្ឋថ្នាក់ជាតិ ឬស្ថាប័នសិទ្ធិមនុស្សថ្នាក់តំបន់។ សហគមន៍ក៏អាចស្វែងរកការគាំទ្រពីស្ថាប័នអង្គការសហប្រជាជាតិដែលពាក់ព័ន្ធផងដែរ។
- ការប្រើប្រាស់យន្តការគណនេយ្យភាពខាងក្រៅ៖ គម្រោងជាច្រើនមានប្រភពមូលនិធិពីខាងក្រៅ ដូចជាមកពីធនាគារអភិវឌ្ឍន៍ ឬអ្នកផ្តល់កម្ចីផ្សេងទៀត។ ជារឿយៗ ពួកគេមានគោលការណ៍ណែនាំអំពីសង្គមនិងបរិស្ថាន ព្រមទាំងយន្តការដែលអាចដាក់បណ្តឹងបាន ប្រសិនបើអ្នកខ្ចី (ក្រុមហ៊ុនឬរដ្ឋាភិបាល) មិនអនុវត្តតាមគោលការណ៍ណែនាំទាំងនោះ។ ក្រុមហ៊ុនមួយចំនួន ចូលរួមនៅក្នុងគម្រោងពហុភាគី ឬគម្រោងដែលមានការផ្តល់វិញ្ញាបនបត្រវិនិយោគពហុភាគី ហើយអាចមានការប្តេជ្ញាចិត្តនិងកាតព្វកិច្ច ព្រមទាំងយន្តការដែលអាចដាក់បណ្តឹងបាន ប្រសិនបើពួកគេបានរំលោភបំពានទៅលើគោលការណ៍ទាំងនេះ។ វិធានការផ្សេងទៀតមកពីប្រទេសនានាដែលជាសមាជិករបស់អង្គការសម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ (OECD) ដែលមានយន្តការ ថ្នាក់ជាតិសម្រាប់ទទួលបណ្តឹងពីសហគមន៍។
- យន្តការដោះស្រាយបណ្តឹងថ្នាក់មូលដ្ឋាន៖ គេរំពឹងថាសកម្មភាពធុរកិច្ច ត្រូវមានយន្តការដោះស្រាយបណ្តឹងនៅថ្នាក់មូលដ្ឋានរួចជាស្រេច សម្រាប់ដោះស្រាយផលប៉ះពាល់របស់គម្រោង។ ប្រសិនបើគ្មានយន្តការនោះទេ ឬមានដែរប៉ុន្តែតាក់តែងឡើងដោយមិនបានល្អ នោះការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM) អាចផ្តល់នូវវិធីមួយក្នុងការដោះស្រាយបញ្ហានានា ដែលបានរកឃើញតាមរយៈការប្រើប្រាស់ឧបករណ៍ផ្សេងៗទៀត។
- ដំណើរការផ្សេងទៀត សម្រាប់ដោះស្រាយបញ្ហានៅក្នុងមូលដ្ឋាន (ដែលមានភាពជាក់លាក់តាមបរិបទ)

## ៣. LEAD និងសិទ្ធិមនុស្ស

គ្រប់យន្តការ និងសកម្មភាព របស់LEAD មានបំណងជួយសហគមន៍ក្នុងការពារសិទ្ធិរបស់ខ្លួនដែលកំពុងតែប្រឈមដោយសកម្មភាពធុរកិច្ចនិងគម្រោងអភិវឌ្ឍន៍នានា។ សិទ្ធិមនុស្ស រួមមានសិទ្ធិនីតិវិធី ដូចជាសិទ្ធិក្នុងការទទួលបានព័ត៌មាន សិទ្ធិក្នុងការចូលរួមក្នុងការសម្រេចចិត្ត និងសិទ្ធិទទួលបានដំណោះស្រាយ។ សិទ្ធិទាំងនោះ ក៏រួមមានបញ្ចូលនូវសិទ្ធិសារធាតុ ដូចជាសិទ្ធិក្នុងការទទួលបានការរស់នៅសមរម្យ សិទ្ធិទទួលបានកិច្ចគាំពារសុខភាព និងសិទ្ធិផ្សេង ទៀត។ ឧបករណ៍នានាដែល រួមមានសកម្មភាពប្រមូលព័ត៌មាននិងសកម្មភាពចូលរួមក្នុងដំណើរការផ្សេងទៀត អាចជួយដល់សហគមន៍ក្នុងការអនុវត្តសិទ្ធិនីតិវិធីបាន កាន់តែមានប្រសិទ្ធភាព។ ការអនុវត្តសិទ្ធិនីតិវិធីទាំងនេះ ជួយការពារដល់សិទ្ធិសារធាតុផងដែរ។ ឧទាហរណ៍ ប្រសិនបើហានិភ័យនៃ កាកសំណល់ចេញពីការធ្វើអាជីវកម្មរ៉ែ ហូរចូលទៅក្នុងទឹករបស់អ្នកដោយសារតែសកម្មភាពគម្រោងអាជីវកម្មរ៉ែ នោះសិទ្ធិ ផ្សេងៗទៀតអាចទទួលរងផលប៉ះពាល់។ តាមរយៈការប្រើប្រាស់សិទ្ធិក្នុងការទទួលបានព័ត៌មាន និងសិទ្ធិក្នុងការចូលរួមសម្រេចចិត្ត អ្នកអាចកាត់បន្ថយ ឬទប់ស្កាត់ភយន្តរាយទាំងអស់នោះបាន។ តាមរយៈការប្រើប្រាស់សិទ្ធិរបស់អ្នកក្នុងការទទួលបានដំណោះស្រាយសមរម្យ អ្នកអាចទាមទាសំណងបាន ប្រសិនបើ សិទ្ធិសារធាតុទាំងនោះ ត្រូវបានរំលោភបំពាន។

---

សិទ្ធិទាំងនេះ មានលើកឡើងច្បាស់នៅក្នុងឧបករណ៍ផ្សេងៗ ដោយរួមទាំង សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ព្រមទាំងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស សេចក្តីប្រកាសទីក្រុងរីយ៉ូ និងគោលនយោបាយការពារសុវត្ថិភាពរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិភាគច្រើន (IFIs)។

សិទ្ធិនីតិវិធីដូចជាសិទ្ធិទទួលបានព័ត៌មាន សិទ្ធិចូលរួមក្នុងការសម្រេចចិត្ត សិទ្ធិទទួលបានដំណោះស្រាយសរម្យត្រូវបានទទួលស្គាល់ថាជា "សិទ្ធិជាមូលដ្ឋាន" ហើយត្រូវបានដាក់បញ្ចូលទៅក្នុងលិខតតុបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស ដូចជាសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ នៅក្នុងបរិបទធុរកិច្ច និងសិទ្ធិមនុស្ស គោលការណ៍នៃណាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្សរបស់អង្គការសហប្រជាតិ បានដាក់បញ្ចូលផ្នែកសំខាន់ទាំងមូលស្តីពីដំណោះស្រាយ ការគោរពសិទ្ធិមនុស្ស ព្រមទាំងកាតព្វកិច្ចរបស់វិស័យឯកជនចំពោះសិទ្ធិមនុស្ស ។ នៅក្នុងបរិបទនៃការអភិវឌ្ឍ និងបរិស្ថាន គោលការណ៍ទី១០ នៃសេចក្តីប្រកាសទីក្រុងរីអូ បានបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិទាំងបីនេះ។ គោលនយោបាយណែនាំ គោលនយោបាយការពារ ព្រមទាំងសេចក្តីណែនាំ របស់គ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀតបានអំពីពាវនាវអោយមានការផ្តល់ព័ត៌មាន ការពិគ្រោះយោបល់ ព្រមទាំងពិភាក្សាអំពីភាពចាំបាច់នៃដំណើរការដោះស្រាយវិវាទ។ ជាពិសេស ប្រទេសមួយៗអាចមានច្បាប់ ឬបទបញ្ញត្តជាក់លាក់អំពីសិទ្ធិទាំងនេះ។

យន្តការរបស់ LEAD គឺដើម្បីលើកកម្ពស់សិទ្ធិជាមូលដ្ឋានទាំងនេះ។ វាជួយដើម្បីបង្ហាញអោយឃើញនូវច្បាប់ បទបញ្ញត្តិ យន្តការដែលពាក់ព័ន្ធ ព្រមទាំងការប្តេជ្ញាចិត្តរបស់គម្រោងនីមួយៗនូវចំនុចខ្លាំងក្នុងការការពារសិទ្ធិទាំងនោះ។

**ការទទួលបានព័ត៌មាន៖** សហគមន៍មានសិទ្ធិ ក្នុងការឆ្វេងយល់ឲ្យបានក្បោះក្បាយ អំពីអ្វីដែលកំពុងតែកើតឡើង នៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោងណាមួយ។ ក៏ប៉ុន្តែនៅក្នុងគម្រោងភាគច្រើនបំផុតនោះ ការទទួលបានព័ត៌មាន នៅតែជាឧបសគ្គដ៏សំខាន់ធំមួយសម្រាប់សហគមន៍។ ឧបករណ៍ប្រមូលព័ត៌មាន ដូចជា ការធ្វើផែនទីធនធានធម្មជាតិសហគមន៍ (CNRM) និងការវាយតម្លៃហេតុប៉ះពាល់សុខភាពសហគមន៍ (CHIA) ជួយសហគមន៍ឲ្យប្រមូលព័ត៌មានដោយខ្លួនឯង និងអាចជួយដល់សហគមន៍ក្នុងការកំណត់ អំពីថាតើព័ត៌មានអ្វីខ្លះដែលទាក់ទងជាមួយនឹងគម្រោងដែលគេនៅត្រូវការការកំណត់អំពីភយន្តរាយដែលអាចកើតឡើង កំណត់អំពីអ្នកពាក់ព័ន្ធ ព្រមទាំងអំពីកាតព្វកិច្ចរបស់តួអង្គនីមួយៗ។ ការធ្វើផែនទីដែលជាធាតុផ្សំរបស់ឧបករណ៍ LEAD នេះអាចជួយកំណត់ថា តើសហគមន៍អាចស្វែងរកឬទាមទារព័ត៌មានទាំងអស់នោះពីកន្លែងណានិងពីអ្នកណា។

**សិទ្ធិក្នុងការចូលរួមក្នុងការសម្រេចចិត្ត៖** សិទ្ធិក្នុងការចូលរួមក្នុងការសម្រេចចិត្ត ជាចំណុចស្នូលក្នុងការការពារសិទ្ធិសារធាតុ។ លក្ខខណ្ឌតម្រូវសម្រាប់សកម្មភាពនានា ដូចជា "ការចូលរួមអោយបានពេញលេញ" ការពិគ្រោះយោបល់ និងការព្រមព្រៀងដោយសេរី ជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់ នៅក្នុងករណីសហគមន៍ជនជាតិដើមភាគតិច ផ្តល់នូវវេទិកាមួយសម្រាប់សហគមន៍ ផ្តល់ធាតុចូលរបស់ខ្លួន លើកឡើងពីក្តីបារម្ភ និងស្នើឡើងនូវដំណោះស្រាយ ឬជម្រើសផ្សេងទៀត។ សកម្មភាពចូលរួមដែលមានប្រសិទ្ធភាព អាចជះឥទ្ធិពលទៅលើការសម្រេចចិត្តនៃគម្រោង ដើម្បីការធ្វើអោយប្រាកដថាគម្រោងនោះ អាចបន្តដំណើរទៅមុខបាន លុះត្រាតែមានយន្តការបញ្ចៀស ឬកាត់បន្ថយភយន្តរាយ ទៅលើសហគមន៍ដល់កម្រិតអប្បបរមា ។ នៅក្នុងករណីមួយចំនួន ការចូលរួមរបស់សហគមន៍ អាចឈានដល់ការបញ្ឈប់គម្រោងដែលបង្កភយន្តរាយទាំងអស់នោះ។ ឧបករណ៍ LEAD ទាំងអស់ អាចជួយសហគមន៍ឲ្យប្រើប្រាស់សិទ្ធិក្នុងការចូលរួមរបស់ខ្លួនបានពេញលេញ។ ការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមានភាពជាប់ទាក់ទងជិតស្និទ្ធបំផុត ដោយសារតែវា ផ្តោតទៅលើសិទ្ធិក្នុងការចូលរួមជាក់លាក់របស់សហគមន៍។ ការប្រើប្រាស់លទ្ធផលដែលកើតចេញមកពីសកម្មភាពប្រមូលព័ត៌មាន ដូចជា ការធ្វើផែនទីធនធានធម្មជាតិសហគមន៍និងការ

វាយតម្លៃហេតុប៉ះពាល់បញ្ហាសុខភាពដែលសហគមន៍បានចងក្រង គឺជាឯកសារអំពីបរិស្ថាននិងផលប៉ះពាល់ដែលអាចកើតឡើងពីគម្រោងនៅក្នុងសហគមន៍ គឺជាការជួយពង្រឹងជំហររបស់សហគមន៍ នៅពេលចូលរួមក្នុងដំណើរការនេះ។ នៅពេលកំពុងរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM) សហគមន៍អាចប្រើប្រាស់សិទ្ធិក្នុងការចូលរួមបាន។

**សិទ្ធិក្នុងការទទួលបានដំណោះស្រាយសមរម្យ៖** សិទ្ធិក្នុងការទទួលបានដំណោះស្រាយសមរម្យ មានសារៈសំខាន់ខ្លាំងណាស់ ក្នុងការផ្តល់ការគោរពដល់សិទ្ធិមនុស្ស។ នៅពេលដែលគម្រោងណាមួយបង្កភយន្តរាយនិង បំពានសិទ្ធិមនុស្ស សហគមន៍មានសិទ្ធិទទួលបានដំណោះស្រាយសមរម្យ។ សិទ្ធិទទួលបានដំណោះស្រាយសមរម្យនេះ រួមបញ្ចូលទាំងការទទួលបាននូវយន្តការដោះស្រាយ ដែលមានប្រសិទ្ធភាព និងដំណោះស្រាយសមរម្យទៅលើសិទ្ធិសារធាតុ ដែលទទួលរងការរំលោភបំពាន។ ការអភិវឌ្ឍ និងការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM) ជួយដល់ការអនុវត្តសិទ្ធិនេះតាមរយៈការលើកឡើងអោយច្បាស់ ថាតើដំណើរការដោះស្រាយ នៅមូលដ្ឋានបែបណាដែលមានលក្ខណៈត្រឹមត្រូវសមស្រប និងថាតើដំណោះស្រាយប្រកបដោយភាពយុត្តិធម៌មាន លក្ខណៈ ដូចម្តេច ព្រមទាំងទាមទាអោយមានការអនុវត្ត ដំណើរការទាំងអស់នោះ។ សកម្មភាពបំពេញបន្ថែមផ្សេងទៀត នៅក្នុងយន្តការ LEAD ដូចជាសកម្មភាពធ្វើផែនទី និងយុទ្ធសាស្ត្រ ដំណើរការតាមយន្តការយុត្តាធិការ និងពាក់កណ្តាលយុត្តាធិការ អាចពង្រឹងសិទ្ធិទទួលបានដំណោះស្រាយសមរម្យ តាមរយៈការកំណត់ឲ្យបាននូវជម្រើស ស្តីពីដំណោះស្រាយ ដែលពាក់ព័ន្ធផ្សេងទៀត ព្រមទាំងធ្វើការសម្រេចចិត្ត ជាយុទ្ធសាស្ត្រអំពីជម្រើសមួយណាដែលត្រូវប្រើ។ អ្វីដែលសំខាន់នោះ គឺថាការចូលរួមនៅក្នុងការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM) មិនគួររារាំងដល់ ការទទួលបាននូវយន្តការដំស្រាយផ្សេងទៀតឡើយ។

## ៤. របៀបប្រើប្រាស់ឧបករណ៍នេះ

សំណុំឧបករណ៍នេះ មានបំណងធ្វើឲ្យមានភាពបត់បែននិងអាចសម្របបានទៅតាមបរិបទសហគមន៍នីមួយៗ។ ជាការមានប្រយោជន៍ក្នុងការចាប់ផ្តើមដោយការពិចារណាទៅលើកត្តាជាបឋមមួយចំនួនអំពីទំនាក់ទំនងរបស់អ្នកជាមួយនឹងសហគមន៍ និងអំពីសមត្ថភាពរបស់សហគមន៍នាពេលបច្ចុប្បន្ន ចំណេះដឹងអំពីគម្រោង វត្ថុបំណង និងការគាំទ្រដែលសហគមន៍ចង់បាន។

ប្រសិនបើអ្នកមិនបានធ្វើការជាមួយនឹងសហគមន៍នេះពីមុនមកទេ ឬប្រសិនបើមានបញ្ហាជំនឿទុកចិត្តជាមួយអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនោះ អ្នកនឹងត្រូវកសាង ឬពង្រឹងទំនាក់ទំនងជាមួយសហគមន៍។ ប្រសិនបើការផ្តោត ជាបឋមចម្បងរបស់អ្នក គឺការកសាងទំនាក់ទំនងល្អ ភាពជាអ្នកដឹកនាំ និងផលប្រយោជន៍ជាមួយសហគមន៍ ឬប្រសិនបើផ្តោតទៅលើការគាំទ្រពួកគេឲ្យយល់កាន់តែប្រសើរអំពីព័ត៌មានស្តីពីគម្រោងនេះអំពីរបៀបដែលគម្រោងអាចប៉ះពាល់ទៅលើពួកគេ និងសិទ្ធិរបស់ពួកគេនោះ វាអាចមានប្រយោជន៍ក្នុងការចាប់ផ្តើម ជាមួយនូវសកម្មភាពកសាងសហគមន៍។ ប្រសិនបើអ្នកមានទំនាក់ទំនងជាមួយសហគមន៍រួចហើយ ហើយពួកគេបានយល់អំពីគម្រោងនិងយល់អំពីគោលដៅទូលំទូលាយរបស់ខ្លួនហើយនោះ អ្នកអាចធ្វើការជាមួយគ្នាដើម្បីកំណត់អំពីគោលដៅជាក់លាក់ និងកសាងយុទ្ធនាការមួយ។



ក្នុងការធ្វើការរួមគ្នាជាមួយសហគមន៍ អ្នកជួយសម្រួលដល់ការសម្រេចចិត្តរបស់ ពួកគេទាក់ទងនឹងឧបករណ៍ណាមួយ ដែលត្រូវប្រើប្រាស់ ដោយផ្អែកទៅលើអាទិភាពនិងគោលដៅរបស់ពួកគេ។ ឧបករណ៍ជាក់លាក់ទាំងឡាយអាចមាន ភាពជាប់ទាក់ទងគ្នាតិច ឬច្រើន ក្នុងពេលវេលាផ្សេងគ្នានៅពេលដែលវត្ថុបំណងរបស់សហគមន៍មានការផ្លាស់ប្តូរ និង/ឬ ស្ថានភាពគម្រោងមានការប្រែប្រួល។ ឧបករណ៍ទាំងនេះបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ហើយអាចជាមូលដ្ឋាន ក្នុងការកសាងយុទ្ធនាការអោយគ្នាទៅវិញទៅមកដែរ។ ឧទាហរណ៍ ការធ្វើផែនពីធនធានធម្មជាតិសហគមន៍អាចផ្តល់ព័ត៌មាន ដើមគ្រាមួយ ដែលអាចប្រើសម្រាប់វាស់វែងផលប៉ះពាល់ ដែលអាចកើតឡើងក៏ដូចជាការវាយតម្លៃ ហេតុប៉ះពាល់សុខភាព សហគមន៍ដែរ។ លទ្ធផលនៃការធ្វើផែនទីធនធានធម្មជាតិសហគមន៍ និងការវាយតម្លៃហេតុប៉ះពាល់ សុខភាពសហគមន៍ អាចយកទៅប្រើប្រាស់នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក៏ដូចជាប្រើនៅពេលរៀបចំ បង្កើតការរចនាយន្តការតវ៉ាកម្រិតប្រតិបត្តិការដែលដឹកនាំដោយសហគមន៍ (CD-OGM)។ ការចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់ បរិស្ថានអាចផ្តល់ភស្តុតាងក្នុងការស្វែងរកដំណោះស្រាយ ប្រសិនបើធាតុចូលទាំងឡាយ ដែលផ្តល់ដោយសហគមន៍ ក្នុងអំឡុងពេលដំណើរការពិគ្រោះយោបល់ មិនត្រូវបានអនុវត្តតាម ហើយផលប៉ះពាល់បានកើតឡើង។ ការអភិវឌ្ឍយន្តការដោះស្រាយបណ្តឹង ដែលដឹកនាំការប្រព្រឹត្តទៅដោយសហគមន៍ ក៏អាចផ្តល់នូវឥទ្ធិពល សម្រាប់ការចរចាមួយ ក្នុងអំឡុងពេលពិគ្រោះយោបល់ (ជារឿយៗនៅដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) ដែលសហគមន៍អាចដាក់លក្ខខណ្ឌ ទៅលើការទទួលយកគម្រោង លុះត្រាតែក្រុមហ៊ុនយល់ព្រមក្នុងការទទួលយក យន្តការដោះស្រាយបណ្តឹង ដែលដឹកនាំ ការប្រព្រឹត្តទៅដោយសហគមន៍។


EarthRights International